CAMBODIAN

# សាលារៀនសាធារណៈក្រុងស៊ីអាថល់ – ការកំណត់សំគាល់សិទ្ធ ក្រោមសិទ្ធិអប់រំគ្រួសារ និងច្បាប់ឯកជន (FERPA) ហើយនិងពាក្យសុំការជ្រើសរើស

**ក្រោមសិទ្ធអប់រំគ្រួសារនិងច្បាប់ឯកជន (FERPA), មាតាបីតារបស់សិស្សានុសិស្សដែលមានអាយុក្រោម 18 ឆ្នាំ, ហើយនិងសិស្សានុសិស្សដែលមានអាយុ 18 ឆ្នាំឡើងទៅ (មានសិទ្ធជំច្បាស់) ទៅលើបញ្ជីសិក្សារបស់សិស្សានុសិស្ស។ បើសិនណាសិស្សអាយុ 18 ឆ្នាំ, ទោះបីរៀននៅសាលាបឋមសិក្សា, ឬរស់នៅជាមួយមាតាបីតា ឬអ្នកអាណាព្យាបាលក្តី, សិស្សមានសិទ្ធិគ្រប់គ្រាន់នៅក្រោមច្បាប់នេះ។ សិទ្ធិទាំងនោះមាន:**

(1) សិទ្ធិពិនិត្យនិងមើលសារឡើងវិញនូវបញ្ជីសិក្សាសិស្សបានក្នុងរយះពេល 45 ថ្ងៃ ដែលសាលារៀនសាធារណៈក្រុងស៊ីអាថល់ (SPS) បានទទួលសេចក្តីសុំតម្រូវជាលាយលក្ខណ៏អក្សរ។

(2) សិទ្ធិតម្រូវការផ្លាស់ប្តូរបញ្ជីសិក្សាសិស្ស ដែលមាតាបីតាឬសិស្សជឿជាក់ថាមិនច្បាស់លាស់ឬមិនត្រឹមត្រូវ។ បើសាលារៀនសាធារណៈក្រុងស៊ីអាថល់ សម្រេចថាមិនធ្វើការផ្លាស់ប្តូរតាមការតម្រូវរបស់មាតាបីតាឬសិស្សនោះទេ, សាលារៀននិងពន្យល់ពិសិទ្ធិនៃការតវ៉ានេះផងដែរ។ ពត៌មានបន្ថែមពីការតវ៉ានេះ និងផ្តល់ឱ្យមាតាបីតានិងសិស្សនៅពេលដែលមានធ្វើកំណត់សិទ្ធនៃការតវ៉ា។

(3) សិទ្ធិយល់ព្រមបញ្ចេញអត្តសញ្ញាណដែលមាននៅក្នុងបញ្ជីសិក្សាសិស្ស, លើកលែងតែបន្ថែម ដែលច្បាប់ FERPA អនុញ្ញាតិឱ្យបញ្ចេញដោយមិនបាច់យល់ព្រម។ លើកលែងតែមួយដែលអនុញ្ញាតិដោយមិនបាច់យល់ព្រម គឺការបញ្ចេញឱ្យបុគ្គលិកសាលារៀនដែលមានសារះសិក្សាស្របច្បាប់។ បុគ្គលិកសាលារៀនគឺជាអ្នកស៊ីឈ្នួលបំរើសាលារៀនសាធារណៈក្រុងស៊ីអាថល់, មានបុគ្គលិកការិយាល័យ, អ្នកទទួលខុសត្រូវ, គ្រូបង្រៀន, ឬសមាជិកនៃអ្នកគាំទ្រ (មានគ្រូពេទ្យនិងពូលីស), លោកគ្រូអ្នកគ្រូ, ក្រុមប្រឹក្សាសាលារៀន, មនុស្សឬរោងចក្រដែលសាលារៀនបានចុះកុងត្រាឱ្យធ្វើការកិច្ចការអ្វីមួយ (ដូចជា: លោកមេធាវី, អ្នកផែកឆេរលុយកាក់, ទីប្រឹក្សាផ្នែកខាងពេទ្យ, ឬអ្នកព្យាបាលរោគជាដើម), ឬមាតាបីតា ឬសិស្សដែលបំរើសាលារៀន ជាសមាជិកសហគមន៏ពេញច្បាប់, ដូចជាអ្នកមើលខាងចរិយាសម្បត្តិ ឬគណះកម្មាធិការដោះស្រាយខាងអំពើអយុត្តិធម៏ ឬអ្នកជំនួយពីសាលារៀនផ្សេងទៀតមកធ្វើកិច្ចការអ្វីមួយ។ ភ្នាក់ងារសាលារៀនដែលមានសារះសិក្សាស្របច្បាប់ បើសិនជាត្រូវការមើលសារឡើងវិញនូវបញ្ជីសិក្សាដើម្បីបំពេញនូវការទទួលខុសត្រូវរបស់គេ។ តាមតម្រូវ, សាលារៀនសាធារណៈក្រុងស៊ីអាថល់បញ្ចេញបញ្ជីសិក្សាសិស្ស ដោយមិនបាច់មានការអនុញ្ញាតិមកពីអ្នកទទួលខុសត្រូវសាលារៀនផ្សេងទៀត ដែលសិស្សទៅ ចុះឈ្មោះចូលរៀនទេ។

(4) សិទ្ធធ្វើការទិទានទៅក្រសួងសិក្សាធិការសហរដ្ឋ ពិការបរាជយ៏នៃសាលារៀនសាធារណៈក្រុងស៊ីអាថល់ ដែលមានការតម្រូវច្បាប់ FERPA។ ការទិទានដោយមានជាលាយលក្ខណ៏អក្សរត្រូវធ្វើផ្ញើរទៅការិយាល័យទិទានច្បាប់គ្រួសារ, ក្រសួងសិក្សាធិការសហរដ្ឋ, ដែលមានអាសយ័ដ្ឋាន: Family Policy Compliance Office, U.S. Department of Education, 400 Maryland Avenue. S.W., Washington, D.C. 20202-4605.

**ពត៌មានតាមសៀវភៅរាយឈ្មោះនិងទីលំនៅ: ក្រោមច្បាប់ FERPA, ពត៌មានដូចតទៅនេះទុកជាសាធារណះឬជា "សៀវភៅរាយឈ្មោះ" និងអាចបញ្ចេញឱ្យទៅនរណាម្នាក់ក៏បានដែរ, ដោយរួមទាំងអ្នកកាសែត, មហាវិទ្យាល័យនិងសាកលវិទ្យាល័យ, ទាហាន, ក្រុមយុវជន, និងអ្នកឱ្យខ្ចីលុយសិក្សា, លុះត្រាតែលោកអ្នកប្រាប់សាលារៀនក្រុងស៊ីអាថល់ថា លោកអ្នកមិនចង់ឱ្យបញ្ចេញពត៌មានដូចជា: ឈ្មោះ, អាសយ័ដ្ឋាន, លេខទូរសព្ទ័, អាសយ័ដ្ឋាន electronic, រូបថត, ថ្ងៃខែកំណើត, ថ្ងៃខែចុះឈ្មោះចូលរៀន, កំរិតថ្នាក់រៀន, ឋានះចុះឈ្មោះ, សញ្ញាបំត្រឬពានវង្វាន់ដោយបានទទួល, សិក្ខាភាពខាងអ្វីមួយ (រៀនយកមុខវិជ្ជាអ្វីមួយ), ការចូលរួមក្នុងការទទួលស្គាល់នៃសកម្មភាពនិងក្រុមកីឡា, អ្នកលើកសាច់ដុំនិងអ្នកលោតហាក់យកកំពស់, សាលារៀនថ្មីៗឬកម្មវិធីដែលបានចូលរួម, និងពត៌មានផ្សេងៗទៀតដែលជាទូទៅសំគាល់ថាគ្មានទោសពៃ ឬរំលោភដល់សិទ្ធិឯកជនបើគេបញ្ចេញវាទៅ។**

## ការបញ្ចេញពត៌មានតាមសៀវភៅរាយឈ្មោះរបស់សិស្សានុសិស្សចាប់ពីថ្នាក់មត្តេយ្យសាលាទៅដល់ថ្នាក់ទីប្រាំ (Pre-K ទៅដល់ 8 )

ក្នុងនាមលោកអ្នកជាមាតាបិតាឬអ្នកអាណាព្យាបាលនៃសិស្សានុសិស្សសាលារៀនមត្តេយ្យសាលា លោកអ្នកមានសិទ្ធជ្រើសរើសពីរ (2) អំពីពត៌មានដែលមាននៅក្នុងសៀវភៅរាយឈ្មោះសិស្សានុសិស្សរបស់លោកអ្នក ដែលលោកអ្នកត្រូវការបញ្ចេញឬក៏អត់។ ពេលណាក្រដាសនេះបានបំពេញ និងបានផ្ញើទៅសាលារៀនវិញហើយ, ការជ្រើសរើសរបស់លោកអ្នកនិងអាត់តាម electronically ហើយមិនអាចប្តូផ្លាស់បានឡើយ លុះត្រាណាតែលោកអ្នកបំពេញក្រដាសនេះ ហើយផ្ញើទៅសាលារៀនសារជាថ្មីម្តងទៀត។ សូមលោកអ្នកគូសខ្វែងប្រអប់នៅខាងក្រោម ហើយបញ្ជូនក្រដាសនេះទៅសាលា ដែលកូនលោកអ្នករៀនវិញ **ឱ្យបាននៅថ្ងៃទី 1st ខែតុលា** ខាងមុខនេះ។ បើមាតាបិតាឬអ្នកអាណាព្យាបាលមិនបានគូសខ្វែងប្រអប់ណាមួយទេ ឬមិនបានបញ្ជូនក្រដាសនេះត្រឡប់វិញទេ, សាលារៀនសាធារណៈក្រុងស៊ីអាថល់បានចាត់ទុកថា លោកអ្នកយល់ព្រមជ្រើសរើសយកប្រអប់ **A** ហើយ។

**សំរាប់សិស្សានុសិស្ស ថ្នាក់មត្តេយ្យសាលា – ថ្នាក់ទីប្រាំបី (Pre-K ទៅដល់ 8 ):**

សូមគូសតែប្រអប់មួយបានហើយ:

A. ☐ ខ្ញុំបានអនុញ្ញាតិឱ្យបញ្ចេញពត៌មានសិស្សានុសិស្សដែលមានឈ្មោះនៅខាងក្រោមនេះ។

B. ☐ ខ្ញុំមិនបានអនុញ្ញាតិឱ្យបញ្ចេញពត៌មានសិស្សានុសិស្សដែលមានឈ្មោះនៅខាងក្រោមនេះទេ លើកលែងមានច្បាប់អនុញ្ញាតិឱ្យ។

*Turn over for Signatures and Grade 9-12 Options*

*CAMBODIAN*

## ការបញ្ចេញពត៌មានតាមសៀវភៅរាយឈ្មោះរបស់សិស្សានុសិស្ស ថ្នាក់ទីប្រាំបួន ទៅដល់ ថ្នាក់ទីដប់ពីរ (9-12)

ក្នុងនាមលោកអ្នកជាមាតាបិតាឬអ្នកអាណាព្យាបាលនៃសិស្សានុសិស្សសាលារៀនវិទ្យាល័យ ឬសិស្សានុសិស្សស្របច្បាប់ (អាយុពី 18 ឆ្នាំឡើងទៅ), លោកអ្នកមានសិទ្ធជ្រើសរើសបី (3) អំពីពត៌មានដែលមាន នៅក្នុងសៀវភៅរាយឈ្មោះសិស្សានុសិស្សរបស់លោកអ្នក ដែលលោកអ្នកត្រូវការបញ្ចេញឬក៏អត់។ ពេលណាក្រដាសនេះបានបំពេញនិងផ្ញើទៅសាលារៀនវិញហើយ, ការជ្រើសរើសរបស់លោកអ្នកនិងអាត់តាម electronically ហើយមិនអាចប្តូផ្លាស់បានឡើយ លុះត្រាណាតែលោកអ្នកផ្ញើរក្រដាសនេះសារជាថ្មីម្តងទៀត។ បើក្រដាសនេះធ្លាប់ផ្ញើម្តងរួចមកហើយ ដោយផ្ញើនៅក្នុងអំឡុងពេលដែលកូនលោកអ្នករៀននៅ មត្តេយ្យសាលារហូតដល់ថ្នាក់ទីប្រាំបី, ការជ្រើសរើសរបស់លោកអ្នកមិនអាចប្តូផ្លាស់បានឡើយ លុះត្រាណាតែលោកអ្នកបំពេញក្រដាសនេះសារជាថ្មី ដោយផ្ញើទៅសាលារៀនជាថ្មីម្តងទៀត។

ការតម្រូវរបស់យោធាអាមេរិកកាំង ដែលមានទៅលើឈ្មោះ, លេខទូរសព្ទ, និងអាសយ័ដ្ឋាន "សិស្សានុសិស្សនៃសាលារៀនបឋមសិក្សា(អនុវិទ្យាល័យ)", លុះត្រាតែមាតាបីតា, អ្នកអាណាព្យាបាល, ឬសិស្ស ស្របច្បាប់ ត្រូវគូសខ្វែងក្នុងប្រអប់ B ឬ C។ ជាទូទៅយោធាស្នើសុំពត៌មាននេះនៅក្នុងខែតុលានៃឆ្នាំសិក្សានិមួយៗ។ បើលោកអ្នកមិនចង់ឱ្យពត៌មាននេះបញ្ចេញទៅឱ្យយោធាទេ, លោកអ្នក**ត្រូវតែ**គូសខ្វែងក្នុង ប្រអប់ B ឬ C រួចហើយផ្ញើទៅវិញឱ្យបាន **នៅថ្ងៃទី 1st ខែតុលា** ដើម្បីធានាកិច្ចការនេះឱ្យទាន់ពេលវេលា។ បើលោកអ្នកមិនចង់ឱ្យពត៌មាននេះ បញ្ចេញទៅឱ្យមហាវិទ្យាល័យ, កន្លែងធ្វើការ, ក្រុម មាតាបិតាបិតា, ឬក្រុមយោធាផ្សេងៗទេ លោកអ្នកត្រូវតែគូសប្រអប់ B។

មាតាបីតានិងអ្នកអាណាព្យាបាលសិស្សានុសិស្សនៅមធ្យមសិក្សា, និងសិស្សានុសិស្សស្របច្បាប់ត្រូវចងចាំថា ការគូសប្រអប់ B ឬ C បានន័យថាសាលារៀនសាធារណះក្រុងស៊ីអាថល់ និងមិនបញ្ចេញបញ្ជីពត៌មានសិស្សទៅឱ្យផ្នែកយោធាទេ។ ប៉ុន្តែមិនមែនមានន័យថា, ផ្នែកយោធាមិនអាចប្រមូលពត៌មានសិស្សពីកន្លែងផ្សេងៗ, ឬចេញពីប្រភពដែលមិនមែនជាតំបន់សាលារៀនបានដែរ។ ជាបន្ថែម, ការគូសខ្វែងប្រអប់ B ឬ C មិនមែនការពារសិស្សានុសិស្សមិនឱ្យនិយាយរកអ្នកមកជ្រើសរើសទាហាននៅសាលារៀននោះទេ។

សូមលោកអ្នកគូសប្រអប់តែមួយនៅខាងក្រោម ហើយបញ្ជូនក្រដាសនេះទៅសាលាដែលកូនលោកអ្នករៀនវិញ **ឱ្យបាននៅថ្ងៃទី 1st ខែតុលា** ខាងមុខនេះ។
បើមាតាបិតាឬអ្នកអាណាព្យាបាលមិនបានគូសប្រអប់ ណាមួយទេ ឬមិនបានបញ្ជូនក្រដាសនេះត្រឡប់ទៅវិញទេ, សាលារៀនសាធារណះក្រុងស៊ីអាថល់បានចាត់ទុកលោកអ្នកថា យល់ព្រមជ្រើសរើសយកប្រអប់ A ហើយ។

**សំរាប់សិស្សានុសិស្ស ថ្នាក់ទីប្រាំបួន – ថ្នាក់ទីដប់ពីរ ( 9 ទៅដល់ 12 ):**

**សូមគូសតែប្រអប់មួយបានហើយ:**

A. ☐ ខ្ញុំបានអនុញ្ញាត្តិឱ្យបញ្ចេញពត៌មានសិស្សានុសិស្សដែលមានឈ្មោះនៅខាងក្រោមនេះ។

B. ☐ ខ្ញុំ**មិន**បានអនុញ្ញាត្តិឱ្យបញ្ចេញពត៌មានសិស្សានុសិស្សដែលមានឈ្មោះនៅខាងក្រោមនេះទេ លើកលែងមានច្បាប់អនុញ្ញាត្តិឱ្យ។ មិនបញ្ចេញទៅឱ្យមហាវិទ្យាល័យ, ក្រុមមាតាបិតាបិតា, ក្រុមយោធា, ឬកន្លែងធ្វើការផ្សេងៗទេ។

C. ☐ ខ្ញុំបានអនុញ្ញាត្តិឱ្យបញ្ចេញពត៌មានសិស្សានុសិស្សដែលមានឈ្មោះនៅខាងក្រោមនេះ, **លើកលែងតែឱ្យទៅខាងផ្នែកយោធា។**

<u>កំណត់សិទ្ធិដែលតម្រូវចុះក្នុងបញ្ជីសាធារណះ:</u>

យោលទៅតាមច្បាប់ Senate Bill លេខ 5533 (2004), ដែលអនុមត RCW 28A.320.170, សាលារៀនសាធារណះត្រូវតែប្រាប់ដល់មាតាបីតា និងអាណាព្យាបាលថាគេមានសិទ្ធិនៅក្រោមច្បាប់ រដ្ឋវ៉ាស៊ីនតោនលេខ (RCW 42.17) តម្រូវយកបញ្ជីសាធារណះចរិយាសម្បត្តិរបស់បុគ្គលិកសាលារៀន។ ដើម្បីដាក់ពាក្យសុំតម្រូវសុំបញ្ជីសាធារណះពីសាលារៀនក្រុងស៊ីអាថល់, សូមបញ្ជូនពាក្យនោះ, ជាលាយលក្ខណ៏អក្សរទៅ: Office of the General Counsel, Attn: Public Records Request, Seattle Public Schools, MS 32-151; PO Box 34165, Seattle, WA 98124, ឬក៏ហ្វាកពាក្យស្នើសុំទៅលេខ (206) 252-0111.

____________________________________
**សរសេរឈ្មោះជាអក្សរធំ** នៃអ្នកចុះហត្ថលេខា

____________________________________ ____________________
**សរសេរឈ្មោះជាអក្សរធំ** របស់សិស្សនិងថ្ងៃខែកំណើត — អត្តលេខរបស់សិស្សប្រចាំសាលារៀន

____________________________________ ____________________
ហត្ថលេខាមាតាបីតា ឬអ្នកអាណាព្យាបាល ឬសិស្សស្របច្បាប់ — ថ្ងៃខែ

**សូមបញ្ជូនពាក្យសុំនេះទៅសាលារៀនកូនរបស់លោកអ្នក**
**តាមសិស្ស ឬតាមប្រៃសណីយ៏សហរដ្ឋ**

បើសិនលោកអ្នកមានសិស្សច្រើន, លោកអ្នកត្រូវតែបំពេញបែកពីគ្នា ម្នាក់មួយៗតាមសាលារៀន។
ពាក្យសុំនេះត្រូវទុកនៅក្នុងបញ្ជីសិស្ស នៅសាលារៀនរបស់ពួកគេ។